ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែសីហា ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកក្កដា ឆ្នាំ២០១៤ | ៤ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

*សេចក្តីព្រាងអនុក្រឹត្យស្តីពី*

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា

កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ហុង ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC ) និង ឯកឧត្តម **ឡាំ ជា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសាធារណៈការនិងដឹកជញ្ជូន។



តំណាងក្រសួងសាធារណៈការនិងដឹកជញ្ជូន បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា ក្នុងគោលបំណងពង្រឹងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីជំរុញ និងលើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្របសម្រួលការដឹកជញ្ជូនទំនិញនិងអ្នកដំណើរឆ្លងកាត់ទៅមកប្រទេសទី៣ ដោយឈរលើមូលដ្ឋានសមភាពនិងផលប្រយោជន៍ទៅវិញទៅមក រដ្ឋាភិបាលនៃប្រទេសទាំងពីរ បានឯកភាពចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ ហើយតាមការបំពេញនីតិវិធីផ្ទៃក្នុងជាបន្តបន្ទាប់ កិច្ចព្រមព្រៀងនេះត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅកម្ពុជា នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ តាមរយៈព្រះរាជក្រឹត្យលេខ នស/រកម/០៦១០/០០៩ និងត្រូវបានចូលជាធរមានរវាងប្រទេសទាំងពីរនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១១។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា បានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម ៖



១.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក។

២.កិច្ចប្រជុំស្តីពីការអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ដែលក្នុងនោះ ភាគីទាំងពីរបានពិនិត្យបទបញ្ញាផ្ទៃក្នុងរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ និងបានជំរុញឲ្យបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅតាមប្រទេសនីមួយៗ ដើម្បីជួយដល់ដំណើរការរបស់គណៈកម្មាធិការនេះ។

៣.នៅក្នុងកិច្ចប្រជុំលើកទី១ រវាងក្រុមការងារនៃក្រសួងសាធារណការនិងដឹកជញ្ជូនកម្ពុជា និងក្រសួងដឹកជញ្ជូនវៀតណាម ដោយមានការចូលរួមផងដែរពីតំណាងកម្មវិធីនាវាចរណ៍នៃគណៈកម្មការទន្លេមេគង្គ នៅថ្ងៃទី២៦ និងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ នៅទីក្រុងហូជីមិញ ភាគីវៀតណាមបានបង្ហាញអំពីសមាសភាពគណៈកម្មាធិការរបស់ខ្លួន និងបានស្នើសុំភាគីកម្ពុជាបង្កើតគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គដែលជាគណៈកម្មាធិការរួមនោះ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃព្រហស្បតិ៍ ទី១៤ ខែសីហា ឆ្នាំ២០១៤ នៅវេលាម៉ោង ៩:០០ នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ឯកឧត្តម អនុប្រធាន និងសមាជិក ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្រសួងសាមី និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ។

២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។

៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា។

៤-បញ្ហាផ្សេងៗ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានណែនាំឲ្យក្រុមប្រឹក្សាអ្នកច្បាប់ឯកភាពគ្នាសរសេរជាគំរូតែមួយនៅក្នុងមាត្រា១ នៃជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅក្នុងទម្រង់នៃការតាក់តែងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នអង្គភាព...ណាមួយ។ មាត្រា១នេះ ត្រូវចែងដោយចាប់ផ្តើមពីពាក្យ "**ត្រូវបានបង្កើតឡើងនូវ...**" ។



ក្រោយពីបានផ្លាស់ប្តូរយោបល់គ្នាយ៉ាងផុលផុស អង្គប្រជុំបានឯកភាពទៅលើទម្រង់និងខ្លឹមរួមរបស់អនុក្រឹត្យទាំង៣ មានការកែសម្រួលឃ្លា និងពាក្យពេចន៍មួយចំនួន។ ចំពោះសេចក្តីព្រាងអនុក្រឹត្យទី២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដោយមានការប្តូរពាក្យ **មជ្ឈមណ្ឌលជាតិ** ទៅជា **និហិតដ្ឋានជាតិ**។ និហិតដ្ឋាន (Repository) សំដៅដល់កន្លែងរក្សាទុកព័ត៌មាន ពាក្យនេះ បានបន្ថែមក្នុងឧសម្ព័ន្ធ។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោង ១១:១០នាទី ក្រោមបរិយាកាសរីករាយ ស្និតស្នាល និងទទួលបានលទ្ធផលវិជ្ជមានតាមការរំពឹងទុក។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១៤*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំខែកក្កដា ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ដឹកនាំដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមសមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកក្កដាឆ្នាំ២០១៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,៤% ធៀបនឹងខែមុននិងកើនឡើង ៤,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញមួយចំនួន

| ក្រុមទំនិញ | | មុខទំនិញ | |
|---|---|---|---|
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ : | +៧,១% | ឧស្ម័ន : | +១៦,៧% |
| ភោជនីយដ្ឋាន : | +៦,៧% | សាច់ជ្រូក : | +១២,០% |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់: | +៦,៥% | ផ្លែឈើ: | +១១,៤% |
| ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ននិងផ្សេងទៀត | +៥,៥% | សាច់គោស្រស់ : | +៧,០% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១២–២០១៤

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហាP | កញ្ញាP | តុលាP | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,៦% | ៤,៥% | ៤,២% | | | |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៧% | ០,៦% | ០,១% | | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |
| ២០១២ | ដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | មុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០% | ១,១% | ០,២% | -០,២% | -០,២% | ០% | |

P: តួលេខខែសីហា កញ្ញា និងតុលាឆ្នាំ២០១៤ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| ប្រភេទ | កក្កដា២០១៤ | មិថុនា២០១៤ | កក្កដា២០១៣ | ប្រភេទ | កក្កដា២០១៤ | មិថុនា២០១៤ | កក្កដា២០១៣ |
|---|---|---|---|---|---|---|---|
| **រ/ដុល្លារ** | ៤០៥០រ/១$ | ៤០៤០រ/១$ | ៤០៦២រ/១$ | **បាត/ដុល្លារ** | ៣១,៩៤បាត/១$ | ៣២,៤៦បាត/១$ | ៣១,២៦បាត/១$ |
| **រ/បាត** | ១២៧រ/១បាត | ១២៤រ/១បាត | ១៣០រ/១បាត | **ដុង/ដុល្លារ** | ២១២២០ដុង/១$ | ២១៣០០ដុង/១$ | ២១១៥០ដុង/១$ |
| **រ/ដុង** | ០,១៩១រ/១ដុង | ០,១៩០រ/១ដុង | ០,១៩២រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកក្កដាឆ្នាំ២០១៤ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១.ចំណូលថវិកាជាតិ**: អនុវត្តបាន៨៩៦,២ពាន់លានរៀល (មធ្យមប្រចាំខែ៩៩% នៃផែនការ) ក្នុងនោះចំណូលចរន្ត ចំនួន ៨៩៣,០ពាន់លានរៀល (មធ្យមប្រចាំខែ ១០៣% នៃផែនការ) និងចំណូលមូលធន៣,១ពាន់លានរៀល។

- ➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ ៤,២% ប៉ុន្តែ កើនឡើង៥៧,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ➢នៅក្នុងចំណូលចរន្ត:
  - ✓ចំណូលសារពើពន្ធមានចំនួន ៧៧២,២ពាន់លានរៀល ថយចុះ:០,១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤៥,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១២–២០១៤ (ពាន់លានរៀល)




  - ✓ចំណូលមិនមែនសារពើពន្ធមានចំនួន ១២០,៨ពាន់លានរៀល ថយចុះ:៧,៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២១០,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ:+១,៨% | (+៣៧,១%) | ➢ នេសាទ:+៤,៥% | (+១៩៦,៣%) |
| ➢ ចំណូលពន្ធដារ: +១៦,២% | (+៣៦,២%) | ➢រុក្ខាប្រមាញ់:-៨៧,៣% | (-៧០,៦%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:+៤១,៤% | (+២៦,៥%) | ➢សម្បទានរ៉ែ:-៤១% | (-១៩%) |
| ✧ កាស៊ីណូ :+៦១,២% | (+១០១%) | ➢ អាកាសចរណ៍ស៊ីវិល:-៥៧,៦% | (+៣៣%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +១០៨% | (+៩០%) | ➢ផលទុននៃសកម្មភាពទេសចរណ៍: -១៧% | (+៥%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +២០,១% | (-១១,៩%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍:+៨៧,៧% | (-៥១,៣%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែន និងទិដ្ឋាការ):+៥២,៨% | (+១៦៩,១%) |
| | | ➢ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ:-១៥,១% | (+១១០៨,៤%) |

**២.២. ចំណាយថវិកាជាតិ :** អនុវត្តបាន ៨៧៨,៤ពាន់លានរៀល(*មធ្យមប្រចាំខែ ៥២% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៧១៦,៣ពាន់លានរៀល (*មធ្យមប្រចាំខែ ៧១% នៃផែនការ*) និងចំណាយមូលធនចំនួន១៦២,១ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន* ចំណាយថវិកាជាតិ កើនឡើង ៥៨,៩%និងកើនឡើង១១,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង៥០,៧% ធៀបនឹងខែមុន និងកើនឡើង១,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន **១៨**ពាន់លានរៀល។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១២–២០១៤
(ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដាឆ្នាំ២០១៤មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៣៩៥៩៧ពាន់លានរៀល កើនឡើង២,៥%ធៀបនឹងខែមុន និងកើនឡើង៣០,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **កំណើន$M_2$** ជារួម បណ្តាលមកពីកំណើនរូបិយវត្ថុក្រៅធនាគារ ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ និងប្រាក់បញ្ញើជារូបិយបណ្ណ។

➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,២% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៨% នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកក្កដា ឆ្នាំ២០១៤



តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៤

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៧% | ១៨,០% | ១៧,៧% | ១៧,៦% | ១៧,២% | ១៦,០% | ១៦,២% | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៤% | ១៣,៥% | ១៣,៨% | ១៣,៨% | ១៣,២% | ១២,២% | ១២,៣% | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកក្កដា២០១៤: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤០៥៧លានដុល្លារ កើនឡើង៥,៨% ធៀបនឹងខែមុន និងកើនឡើង ១៧,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៣០២២ ពាន់លានរៀលកើនឡើង៥,៩% ធៀបនឹងខែមុន និងកើនឡើង៦៧,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | កក្កដា២០១៤ | មិថុនា២០១៤ | កក្កដា២០១៣ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល) | ៣៩០២៨ | ៣៣០៦២ | ២៧៥៣៧ |
| ក្នុងនោះ ជារៀល | មិនទាន់មានតួលេខ | ៤៣៤ | ៤២៩ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | មិនទាន់មានតួលេខ | ៦៥៦៩ | ៤៦០០ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៨៣% | ៥,៩៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១៦,១២% | ១១,៩៣% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,២៧% | ៤,៣៩% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៥០% | ១១,៤២% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកក្កដាឆ្នាំ២០១៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ៣៦ពាន់តោន មានការថយចុះ២៦%ធៀបនឹងខែមុន និងមានការថយចុះ២២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣៨៨,២GWH មានការកើនឡើង ០,៤% ធៀបនឹងខែមុន និងកើនឡើង២៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គសនីមានចំនួន ២៨៣,៣ GWHមានការកើនឡើង ៧៤% ធៀបនឹងខែមុន និងកើនឡើង ១១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤៨៧,៦ លានដុល្លារ មានការថយចុះ១២%ធៀបនឹងខែមុន ប៉ុន្តែ មានការកើនឡើង ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន –កក្កដា២០១៤* | *ចំនួន–មិថុនា២០១៤* | *ចំនួន–កក្កដា២០១៣* |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ២៨ | ២៥ | ១៥ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១២១៦ | ១១៨៨ | ១០១១ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៨ | ២៧ | ១៣ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | 0 | – | ៤ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១១៤,៩ពាន់ម៉ ថយចុះ ៨៤% ធៀបនឹងខែមុននិងថយចុះ ៦៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។បើគិតជាសាច់ប្រាក់ស្មើនឹង៣៣លានដុល្លារថយចុះ ៨៦% ធៀបនឹងខែមុន និងថយចុះ ៦៩% ធៀបនឹង ខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម៉ –កក្កដា២០១៤* | *ពាន់ម៉ –មិថុនា២០១៤* | *ពាន់ម៉ –កក្កដា២០១៣* |
|---|---|---|---|
| ▪ លំនៅឋាន | ៤៥,២ | ១៥៩,៩ | ១៥៦,២ |
| ▪ ឧស្សាហកម្ម | ២៤,១ | ៣៩៤,៧ | ១២០,៤ |
| ▪ទេសចរណ៍ | ១៥,៧ | ៥៧,៧ | ២៣,៨ |
| ▪ផ្សេងៗ | ២៤,៤ | ៣៧,៤ | ២០,៦ |
| អនុញ្ញាតសរុប | ១១៤,៩ | ៧០៣,២ | ៣៥៥,៩ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅឋាន ៣៩% សំណង់ផ្សេងៗ ២១% និងឧស្សាហកម្ម ២១%នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៤.៣. ការទទួលបានការងារ

| *ប្រភេទ* | *នាក់–កក្កដា២០១៤* | *នាក់–មិថុនា២០១៤* | *នាក់–កក្កដា២០១៣* |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ ) | NA | NA | NA |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៦៤១ | ៨៣៨១ | ៥៣៦៤ |
| អ្នកទទួលបានការងារក្នុងប្រទេស | | ៦៩០៥ | ៤០៧៦ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៦៤១ | ១៤៧៦ | ១២៨៨ |

## ➤វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កក្កដា២០១៤ | មិថុនា២០១៤ | កក្កដា២០១៣ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២៤១,១ | ២២១៨,៣ | ៩៤,៦ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣២,៧ | ៣២,១ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៥៦,២<br>៥,២ | ២១១៧,៧<br>(១៩១៨,៧) | ៩៤,៦(១៥,៧) |
| វិស័យទេសចរណ៍ | ១២ | ៤៥,៥ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៤០,២ | ២៣,៩ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៨ | ៤៣ | ១៥ |
| បង្កើតការងារ (ពាន់នាក់) | ១៨,៨ | ៥២,២ | ៧,៧ |

## ➤សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —កក្កដា២០១៤ | ចំនួន—មិថុនា២០១៤ | ចំនួន—កក្កដា២០១៣ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤០០ | ៣៤៨ | ៣១៨ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១០ | ២ | ៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | NA | ៣៨៨ | ២៨២ |

➤**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៦០០,៥ពាន់តោន ថយចុះ ១៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-៩% | (+៣៥%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-២៩% | (-៣%) |
| ▪ កំពង់ផែកំពង់សោម:-៦% | (+១%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៤១% | (-៣៩%) |

## ➤ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.

| ប្រភេទ | ចំនួន(ពាន់នាក់) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៧,៥ | +១២% | +៣៣% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២០,១ | +១៦% | +៣៤% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៨៤,២ | +២៣% | +១៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៨២,៤ | +២០,៨% | +២៦% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៤០,១ | +១៣,២% | +០,៤% |
| ✓ តាមផ្លូវអាកាស | ១៦៩,៤ | +២១,៤% | +១៧,១% |
| ✓ តាមផ្លូវគោក និងទឹក | ១៧០,៧ | +៦,១% | -១២% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកក្កដាមានចំនួន ៣៤៩១,៤៣ាន់លានរៀល (ស្មើនឹង ៨៧២.៧ លានដុល្លារ ស.រ.អា.)ថយចុះ ០,៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៩៧,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២០,៨% | +៣,៤% | រថយន្តសរុប (ព.ល.រ) | +២,២% | +៣៦,៧% |
| ប្រេងម៉ាស៊ូត | +៣៥,៣% | +១០,៩% | រថយន្តសរុប (គ្រឿង) | +៩,៧% | +១៩,៧% |
| ឧស្ម័ន | +៣,៤% | +៨៦,០% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៤២,៧% | +២០,៦% |
| អគ្គិសនីនាំចូល | -៦៣,៣% | -៦៦,៤% | ម៉ូតូ (គ្រឿង) | -៩,៨% | +១៣,២% |
| ដែកសំណង់ | -១៧,៨% | +៨២,៧% | អង្ករ | +៦៣,៨% | +៣៥,២% |
| ស៊ីម៉ង់ត៍ | +០,២% | +៣០,៥% | ផ្លែឈើនិងបន្លែ | +១៣,៤% | +១០៨,៥% |
| គ្រឿងអេឡិចត្រូនិក | -១១,៧% | +១៣៤,៥% | ជីនិងថ្នាំកសិកម្ម | -១៥,៨% | +៦៤,៧% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៣,៧% | +១៥,៦% |

➡ **ការនាំចេញ** ខែកក្កដាឆ្នាំ២០១៤ មានចំនួន ២៩៩៩,៨៣ាន់លានរៀល ស្មើនឹង៧៣៧,៤លានដុល្លារ ស.រ.អា. (៨៥% នៃការនាំចូល)កើនឡើង៤,១%ធៀបនឹងខែមុន និងកើនឡើង១៨,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៥០,៦% | +១៤,៧% | ផលិតផលនេសាទ | +២០,៨% | -២៧,១% |
| វាយនភណ្ឌនិងស្បែកជើង | +៧,៥% | +១១,៥% | កៅស៊ូ | -២២,៨% | +១៣,៣% |
| អង្ករ | +៦,០% | +៧,៥% | | | |

➡ក្នុងខែកក្កដានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៥៤១,៦៣ាន់លានរៀលស្មើនឹង១៣៥,៤លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដាឆ្នាំ២០១៤នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម:

**តារាង ៦.១.** សូចនាករសេដ្ឋកិច្ច សង្គមកិច្ច ដែលមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | អាករនាំចេញ | −៤៤.៤% | −១១.៩% | ក្នុងចំណូលពន្ធគយ នៃចំណូលសារពើពន្ធ |
| ២ | ចំណូលពីប្រៃសណីយ៍និងទូរគមនាគមន៍ | +៨៧,៧% | −៥១.៣% | ក្នុងចំណូលមិនមែនសារពើពន្ធ |
| ៣ | ការនាំចូលផ្លែឈើនិងបន្លែ | +១៣,៤% | +១០៨,៥% | — |

## ៧) ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

១)ក្នុងការពិចារណាអំពីអត្រាអតិផរណា ក្រុមទំនិញសំខាន់ដែលគួរផ្តោតការយកចិត្តទុកដាក់មាន ម្ហូបអាហារ ផ្ទះសម្បែង និងការដឹកជញ្ជូន។

២)ថ្លៃសេវាដឹកជញ្ជូនអ្នកដំណើរនារដូវបុណ្យជាតិផ្សេងៗ ដូចជាភ្ជុំបិណ្ឌ ចូលឆ្នាំជាដើមតែងតែឡើងថ្លៃយ៉ាងខ្លាំង និងប៉ះពាល់ដល់ជីវភាពដល់អ្នកធ្វើដំណើរដូចជា កម្មករនិយោជិក និងសិស្សានុសិស្ស ដែលប្រើប្រាស់សេវាដឹកជញ្ជូនពីទីក្រុងទៅស្រុកកំណើត និងត្រលប់មកវិញ។

គួររិះរកមធ្យោបាយដើម្បីជួយដឹកអ្នកដំណើរនៅថ្ងៃឈប់សម្រាកពេលមានពិធីបុណ្យជាតិធំៗម្តងៗ ដើម្បីទប់ថ្លៃសេវាដឹកជញ្ជូនកុំឲ្យឡើងថ្លៃហួសហេតុពេក។

៣)អង្គប្រជុំមានការចាប់អារម្មណ៍ថាមានសំណង់មិនស្របច្បាប់មួយចំនួនដូចជាសំណង់ស្ថានីយប្រេងឥន្ធនៈជាដើមដែលជាសំណង់អាចបង្កហានិភ័យយ៉ាងគ្រោះថ្នាក់បំផុតដល់ប្រជាជនដែលរស់នៅក្បែរស្ថានីយទាំងនោះ។

គួរមានលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការបង្កើតនិងការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ។



រូបភាពក្នុងកិច្ចប្រជុំស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់ ECOSOCC នៅទីស្តីការគណៈរដ្ឋមន្ត្រី

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម ឃឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៨/១៤<br>ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំស្តីពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/០៨/១៤<br>ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និសីទអន្តរជាតិលើកទី៥ ស្តីពីភាពជាអ្នកដឹកនាំនៃយុវជនឆ្នើមឆ្នាំ២០១៤ ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភូគីត្រាភ្នំពេញ។ |
| ៣ | ០៦/០៨/១៤<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និសីទអន្តរជាតិលើកទី៥ ស្តីពីភាពជាអ្នកដឹកនាំនៃយុវជនឆ្នើមឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភូគីត្រាភ្នំពេញ។ |
| ៤ | ០៦/០៨/១៤<br>ម៉ោង ១៤:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកមហាសន្និបាតកាកបាទក្រហមកម្ពុជាអាណត្តិទី៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ៥ | ០៧/០៨/១៤<br>ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសសាលក្រមនៃសំណុំរឿង០០២/០១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅអង្គជំនុំជម្រះវិសាមញ្ញតុលាការខ្មែរក្រហម។ |
| ៦ | ០៧/០៨/១៤<br>ម៉ោង ១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទមហាសន្និបាតកាកបាទក្រហមកម្ពុជាអាណត្តិទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ៧ | ១១/០៨/១៤<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតសាកលវិទ្យាល័យន័រតុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៤ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ១២/០៨/១៤ ម៉ោង ០៨:៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងមហាសន្និបាតសមាគមសង្គហសង្គមទីស្តីការគណៈរដ្ឋមន្ត្រី អាណត្តិទី១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៣/០៨/១៤ ម៉ោង ០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមជ្ឈមណ្ឌលជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការសម្របសម្រួល នាវាចរណ៍មេគង្គកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៣/០៨/១៤ ម៉ោង ១៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំជំនួបប្រចាំឆ្នាំលើកទី៤០ និងមហាសន្និបាត នៃវិទ្យាស្ថានអភិវឌ្ឍការផ្សាយតាមរលកធាតុអាកាសអាស៊ី-ប៉ាស៊ីហ្វិកលើកទី១៣ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ១១ | ១៤/០៨/១៤ ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមជ្ឈមណ្ឌលជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៤ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១២ | ១៥/០៨/១៤<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ថ្មីស្តីពីចរាចរណ៍ផ្លូវគោក។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៣ | ១៨/០៨/១៤<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | ១៨/០៨/១៤<br>ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Naga World និងឯកឧត្តម ឧត្តមសេនីយទោ **សូ ណារ៉ា** មេបញ្ជាការរង តំណាងកងហោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់ ស្តីអំពីសំណើសុំពង្រីកបន្ថែមចំណតយន្តហោះនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ១៩/០៨/១៤<br>ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការ ដើម្បីពិភាក្សាលើគម្រោងពង្រីកស្ថានីយអ្នកដំណើរនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប និងពិភាក្សាលើសំណើសុំពង្រីកបន្ថែមចំណតយន្តហោះ សម្រាប់បម្រើសេវាកម្មដឹកជញ្ជូនភ្ញៀវមកស្នាក់នៅសណ្ឋាគារ Naga របស់ក្រុមហ៊ុន Naga World Co.,Ltd នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ១៩/០៨/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ ការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីត្រៀមប្រជុំជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២០/០៨/១៤<br>ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយសក្នុងកិច្ចប្រជុំស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | **២១/០៨/១៤ ម៉ោង ០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតសាកលវិទ្យាល័យប៊ែលធីអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៩ | **២៦/០៨/១៤ ម៉ោង ០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | **២៧/០៨/១៤ ម៉ោង ០៨:០០នាទី** | ចូលរួមស្តាប់បទឧទ្ទេសនាមរបស់ឯកឧត្តម **លាន ថៃលាំង** អនុប្រធានគណៈកម្មការកំណែទម្រង់ និងអភិវឌ្ឍន៍ជាតិនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពី "បទពិសោធន៍របស់ប្រទេសចិនលើការកែទម្រង់ស៊ីជម្រៅគ្រប់ជ្រុងជ្រោយ និងការងារវិមជ្ឈការនិងសហវិមជ្ឈការ" នៅខុទ្ទកាល័យគណៈកម្មាធិការកណ្តាល។ |
| ២១ | **២៧/០៨/១៤ ម៉ោង ១៧:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | **២៨/០៨/១៤ ម៉ោង ០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពី គម្រោងវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | **២៨/០៨/១៤ ម៉ោង ១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# គម្រោង RIA និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមគ្នារៀបចំសិក្ខាសាលាពិគ្រោះយោបល់លើប្រកាស ស្តីពីការហ្វឹកហ្វឺនកូនជាង



ឯកឧត្តម **កាន់ ម៉ន** ថ្លែងក្នុងអង្គសិក្ខាសាលា

គម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ ហៅកាត់ថា RIA និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤នេះ រួមសហការគ្នារៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈមួយនៅសណ្ឋាគារភ្នំពេញ ដើម្បីឈានទៅការកែលម្អប្រកាសស្តីពីការហ្វឹកហ្វឺនកូនជាង។

សិក្ខាសាលានាព្រឹកនោះ មានការអញ្ជើញចូលរួមពីឯកឧត្តម **យឹម ណុលសន** នាយកគម្រោង RIA ព្រមទាំងថ្នាក់ដឹកនាំនៃគម្រោង RIA ឯកឧត្តម **កាន់ ម៉ន** រដ្ឋលេខាធិការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងមន្ត្រី និងថ្នាក់ដឹកនាំមកពីវិស័យឯកជនជាច្រើនអ្នកផ្សេងទៀត។

ឯកឧត្តម **ម៉ិច សុខា** អ្នកគ្រប់គម្រោង RIA បានថ្លែងថា សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈគឺជាធាតុមួយ នៃវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីប្រមូលនូវព័ត៌មាន និងទទួលយកនូវមតិយោបល់នានា ដែលជាមូលដ្ឋានក្នុងការវិភាគ និងវាយតម្លៃលើផលប៉ះពាល់ នៃប្រកាសស្តីពីការហ្វឹកហ្វឺនកូនជាង ជូនថ្នាក់ដឹកនាំ ដើម្បីធ្វើការសម្រេចចិត្ត។



ឯកឧត្តម **យឹម ណុលសន** នាយកគម្រោង RIA ក្នុងអង្គសិក្ខាសាលា

សូមបញ្ជាក់ថា គម្រោង RIA គឺជាគម្រោងមួយ ដែលប្រតិបត្តិការដោយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រោមជំនួយហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍអាស៊ី ADB ដែលបច្ចុប្បន្នមានក្រសួងចំនួន ៧ ហើយចូលរួមអនុវត្ត។ ក្រសួងទាំង៧នោះរួមមាន ក្រសួងរ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងពាណិជ្ជកម្ម។

# សិក្ខាសាលាស្តីពី
## ការបញ្ជ្រាបការយល់ដឹងជាសាធារណៈចំពោះ ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដោយមានការជួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ADB បានរៀបចំសិក្ខាសាលស្តីពីការបញ្ជ្រាបការយល់ដឹងជាសាធារណៈចំពោះការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) នៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ សិក្ខាកាមដែលចូលរួមក្នុងអង្គសិក្ខាសាលានេះ មានថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រង និងមន្ត្រីជំនាញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។




ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីថ្លែងបើកអង្គសិក្ខាសាលា

ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC ) បានថ្លែងថា RIA ត្រូវបានគេយកមកអនុវត្តនៅក្នុងប្រទេសជាច្រើន ដែលជាភស្តុតាងមួយថែមទៀតបង្ហាញថា RIA មានប្រយោជន៍។ ប្រទេសសមាជិក OECD ( អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ ) ស្ទើរតែទាំងអស់ បាន ប្រតិបត្តិ RIA យូរមកហើយតែក្នុងទម្រង់ផ្សេងៗគ្នា។



ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC ថ្លែងក្នុងអង្គសិក្ខាសាលា



នៅក្នុងតំបន់អាស៊ាន ប្រទេសវៀតណាម តម្រូវឲ្យអនុវត្ត RIA ដោយបានចែងនៅក្នុងច្បាប់តាំងពីឆ្នាំ២០០៩ មក។ ហើយប្រទេសដទៃទៀត ដូចជាប្រទេសឡាវ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងថៃ ក៏កំពុងតែធ្វើការសាកល្បង RIA ដូចកម្ពុជាដែរ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ថ្លែងបន្តថា ការពិនិត្យ និងកែលម្អលិខិតបទដ្ឋានគតិយុត្ត មកពីបណ្តាក្រសួងស្ថាប័ននានា មានការលំបាក តែបើបានអនុវត្តតាមវិធីសាស្ត្រ RIA ហើយនឹងមានរបាយការណ៍វាយតម្លៃលើផលប៉ះពាល់ច្បាស់លាស់ ភ្ជាប់មកជាមួយនោះការផ្តល់យោបល់នឹងមានភាពងាយស្រួល និងចំណេញពេលវេលាច្រើន។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ថ្លែងបញ្ជាក់ថា « វិធីសាស្ត្រ RIA មានអត្ថប្រយោជន៍ ដោយប្រយោលជាច្រើនទៀត ដូចជា ការកសាងសមត្ថភាពរបស់មន្ត្រី RIA ក្នុងការវិភាគជាប្រព័ន្ធលើទិដ្ឋភាពសេដ្ឋកិច្ចនៃលិខិតបទដ្ឋានគតិយុត្ត នឹងបង្កើនជំនាញធ្វើគោលនយោបាយ ដែលផ្តល់អត្ថប្រយោជន៍ដល់រាជរដ្ឋាភិបាល និងសេដ្ឋកិច្ចទាំងមូល។ ជាការពិតអត្ថប្រយោជន៍ជាប្រយោលបែបនេះ នឹងអាចមានកម្រិតខ្ពស់ជាងផលប្រយោជន៍ផ្ទាល់ ដែលបានមកពីការកាត់បន្ថយបន្ទុកចំណាយកាតព្វកិច្ចទៅទៀត។»

ដោយមើលឃើញពីគុណប្រយោជន៍ខ្ពស់នៃគម្រោង RIA នេះ ក្រសួងចំនួន ៧ហើយ រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងអប់រំ យុវជននិងកីឡា ត្រូវបានដាក់បញ្ចូលឲ្យអនុវត្តគម្រោងមួយនេះ។



ឯកឧត្តម **យឹម ណុលសន** នាយកគម្រោង RIA និងជាអនុប្រធាន ECOSOCC ថ្លែងក្នុងអង្គសិក្ខាសាលា

ដើម្បីជំរុញការយល់ដឹងពីគម្រោងមួយនេះឲ្យបានកាន់តែច្បាស់ថែមទៀតនោះ ក្រុមការងារ

គម្រោង RIA នៃ ECOSOCC បានសហការជាមួយ ADB រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីគម្រោង RIA បានចំនួន ៣១ដង ក្នុងនោះ ការផ្សព្វផ្សាយជាមួយវិស័យឯកជន សង្គមស៊ីវិល ថ្នាក់កម្រិតឧត្តមសិក្សាបានចំនួន ០៧ ជាមួយក្រសួង និង ស្ថាប័នរដ្ឋចំនួន៣៧ អគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា ដោយមានចំនួនសិក្ខាកាម សរុបប្រមាណ ៤.៥០០នាក់បានចូលរួម។

ក្នុងឱកាសថ្លែងបើកអង្គសិក្ខាសាលា ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានលើកឡើងថា អ្នកតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវតែសិក្សាឲ្យបានល្អិតល្អន់ ដើម្បីបញ្ចៀសនូវរាល់ផលប៉ះពាល់អវិជ្ជមានទាំងឡាយ នៅពេលច្បាប់ ឬ បទប្បញ្ញត្តិណាមួយត្រូវបានដាក់ឲ្យអនុវត្ត។ ដើម្បីធ្វើឲ្យច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទទួលបាននូវភាពល្អប្រសើរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជំរុញឲ្យក្រសួង-ស្ថាប័ន ត្រូវអនុវត្តតាមវិធីសាស្រ្ត «វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅកាត់ RIA»។ ប្រទេសនីតិរដ្ឋ គឺត្រូវតែមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងសង្គម និងសេដ្ឋកិច្ច។ តែច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនោះ ត្រូវប្រុងប្រយ័ត្នអំពីផលប៉ះពាល់អវិជ្ជមាននៃបញ្ញត្តិកម្ម ដូចជាការរារាំង ដល់ភាពប្រកួតប្រជែង ឬការដាក់បន្ទុកចំណាយធ្ងន់ធ្ងរទៅលើធុរកិច្ចជាដើម។



*រូបភាពក្នុងសិក្ខាសាលាស្តីពីការបញ្ជៀបការយល់ដឹងជាសាធារណៈចំពោះការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី*

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in